សួស្តីអ្នកទាំងអស់គ្នា បាទ ថ្ងៃនេះយើងនឹងមកជួបគ្នាម្តងទៀត ហើយយើងមានប្រធានបទមួយ ដើម្បីយកមកនិយាយជាមួយនឹងអ្នកទាំងអស់គ្នា បាទ។ ហើយប្រធានបទរបស់យើងនៅក្នុងថ្ងៃនេះ គឺយើងនឹងនិយាយអំពីរដូវរងា បាទ។ រដូវរងាឬក៏រដូវត្រជាក់ អញ្ចឹងតើរដូវរងាឬក៏រដូវត្រជាក់នៅក្នុងប្រទេសកម្ពុជាមានលក្ខណៈយ៉ាងណា? យើងមកមើលរូបភាពទាំងអស់គ្នាតែម្តង។

ដែលនៅក្នុងនោះ នៅក្នុងរូបភាពទី ១ យើងឃើញថាមានក្មេងប្រុសម្នាក់ បាទ គាត់ជាក្មេងប្រុស ហើយគាត់កំពុងតែគេងនៅក្នុងបន្ទប់គេងរបស់គាត់។ អញ្ចឹងក្មេងប្រុសហ្នឹង គាត់គេងនៅក្នុងបន្ទប់គេងរបស់គាត់ដោយដណ្តប់ភួយ។ ដោយយើងឃើញថា នៅក្នុងបន្ទប់គេងរបស់គាត់ គឺមានគ្រែគេងមួយ គាត់កំពុងតែគេងនៅលើគ្រែ ហើយក្បាលរបស់គាត់ គឺកើយនឹងខ្នើយរបស់គាត់។ អញ្ចឹងគាត់គេងកើយខ្នើយ ហើយដណ្តប់ភួយមួយ។ ដោយនៅក្បែរគ្រែរបស់គាត់គឺមានបង្អួចកញ្ចក់មួយ។ បាទ បង្អួចកញ្ចក់ ដែលបង្អួចនោះគឺមានវាំងននចំនួនពីរផ្ទាំង ដែលវាំងននោះគឺនៅខាងមុខបង្អួច ប៉ុន្តែគាត់ពុំបានបិទវាំងននោះទេ ព្រោះគាត់ទុកដើម្បីឲ្យមានពន្លឺចេញចូលនៅក្នុងបន្ទប់គាត់។ យើងឃើញ នៅក្បែរបង្អួចនោះគឺមានរូបថតចំនួនមួយផងដែរ។ ហើយរូបថតរបស់គាត់ ដែលនៅក្បែរបង្អួច គឺគាត់ដាក់នៅក្នុងស៊ុមរូបថត។ អញ្ចឹង គាត់ដាក់រូបថតនៅក្នុងស៊ុមរូបថត ហើយស៊ុមរូបថតនោះ គាត់ព្យួរជាប់ទៅនឹងជញ្ជាំង។ បាទ គាត់បានព្យួរវាដោយប្រើប្រាស់ខ្សែជាមួយនឹងដែកគោល។ អញ្ចឹងគាត់យកដែកគោលដំនៅជាប់ជញ្ជាំង។ បន្ទាប់មកយកខ្សែចងភ្ជាប់នឹងស៊ុមរូបថត។ ហើយគាត់យកខ្សែនោះទៅថ្កក់នឹងដែកគោល។ អញ្ចឹងគាត់ថ្កក់ខ្សែជាមួយនឹងដែកគោល ដើម្បីឲ្យស៊ុមរូបថតជាប់នៅនឹងជញ្ជាំង។ បាទ ដូច្នេះស៊ុមរូបថតអាចជាប់នៅនឹងជញ្ជាំងបាន ដោយសារតែមានខ្សែថ្កក់ជាមួយនឹងដែកគោល។ ហើយយើង បើយើងមើលមកខាង នៅលើក្បាលគ្រែវិញ នៅក្បែរក្បាលគ្រែ បាទ ក្បែរក្បាលគ្រែរបស់ក្មេងប្រុសម្នាក់នោះ គឺមានទូមួយ បាទ កូនទូតូចមួយ ដែលកូនទូនោះគឺមានថតចំនួនបី។ អញ្ចឹងមានថតទូចំនួនបី ដែលនៅក្នុងថតទូនោះគឺយើងអាចដាក់បានសម្ភារៈជាច្រើន បាទ។ មានសម្ភារៈដូចជា យើងអាចដាក់ជាសៀវភៅ កាតាប ឬក៏សម្ភារៈតូចៗជាច្រើនទៀត បាទ។ ដូចជាប៊ិច ឬក៏ទូរស័ព្ទដៃជាដើម។ អញ្ចឹងយើងអាចដាក់នៅក្នុងថតកូនទូនោះបាន។ ចំណែកនៅលើទូ យើងឃើញមានកូននាឡិកាមួយ អញ្ចឹងគាត់មាននាឡិកាមួយនៅលើទូ បាទ។ ព្រោះដើម្បីថាឲ្យគាត់អាចដឹងថា តើម៉ោងប៉ុន្មានហើយ? ពេលណាដែលគាត់អាចត្រូវទៅសាលា ឬក៏ពេលណាគាត់ត្រូវទៅញ៉ាំបាយ? អញ្ចឹងគាត់ដាក់នាឡិកាមួយនៅក្នុងបន្ទប់របស់គាត់ ដើម្បីគាត់មើលម៉ោង គាត់អាចដឹងពីពេលវេលាបាន។ នៅក្បែរនាឡិកានោះ គាត់មានអំពូលតុមួយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បាទ អំពូលលើតុ។ អញ្ចឹងអំពូលយើងមានច្រើន អំពូលមានច្រើនប្រភេទ។ ហើយអំពូលដែលយើងប្រើប្រាស់នៅក្នុងផ្ទះគឺជាទូទៅយើងហៅថាអំពូលម៉ែត្រ បាទ ដែលអំពូលម៉ែត្រយើងតែងតែដាក់នៅលើពិតានផ្ទះ ឬក៏ចាប់ជាប់នឹងជញ្ជាំងផ្ទះ។ ប៉ុន្តែក្មេងប្រុសម្នាក់នេះ គាត់មានអំពូលនៅលើតុ។ បាទ អំពូលនៅលើតុ គឺវាមិនសូវភ្លឺដូចអំពូលម៉ែត្រនោះទេ។ ដែលអំពូលនៅលើតុ វាបំភ្លឺតែត្រឹមនៅលើតុគាត់ ឬក៏នៅក្បែរគ្រែរបស់គាត់តែប៉ុណ្ណោះ។ អញ្ចឹងយើងឃើញថា អំពូលនៅលើតុនេះ គឺគាត់ដាក់នៅក្បែរគ្រែរបស់គាត់នៅលើទូមួយ។ បើយើងមើលនៅក្នុងបន្ទប់គេងនេះ គឺថាក្មេងប្រុសនេះគឺជាអ្នកទីក្រុង។ ព្រោះថា ប្រសិនបើនៅតាមជនបទ គឺពុំសូវមានអំពូលដាក់នៅលើតុនោះទេ គឺគេប្រើតែអំពូលម៉ែត្រ ឬក៏អំពូលដែលចាប់អាគុយ។ អញ្ចឹងក្មេងប្រុសនេះ គាត់រស់នៅទីក្រុង។ ដែលគាត់មើលទៅសម្ភារៈ ដែលគាត់ប្រើប្រាស់នៅក្នុងបន្ទប់គេង គឺមានលក្ខណៈទំនើបជាងអ្នកនៅជនបទ។

ចូលដល់រូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថាក្មេងប្រុសម្នាក់នោះបានក្រោកឡើង។ អញ្ចឹងនៅក្នុងរូបភាពទី ២ គឺក្មេងប្រុសនោះ គាត់ក្រោកពីគេង។ ក៏ប៉ុន្តែគាត់ពុំទាន់បានដើរចេញពីគ្រែនោះទេ ដោយគាត់គ្រាន់តែងើបអង្គុយ។ បាទ មុនគាត់នៅក្នុងរូបភាពទី ១ គាត់គេងនៅលើខ្នើយ ប៉ុន្តែនៅក្នុងរូបភាពទី ២ ក្មេងប្រុសម្នាក់នោះ គឺគាត់ងើបអង្គុយឡើង ដោយជើងរបស់គាត់ដណ្ដប់នៅក្នុងភួយ។ បាទ ជើងរបស់គាត់ គឺដាក់ដណ្ដប់នៅក្នុងភួយ។ ហើយគាត់អង្គុយដោយលើកដៃរបស់គាត់ឡើងលើមួយចំហៀង និងយកមួយចំហៀងទៀត យកមកខ្ទប់មាត់របស់គាត់ដែលកំពុងតែស្វាប។ អញ្ចឹងយើងឃើញថា ក្មេងប្រុសម្នាក់នោះគេងដោយពាក់អាវសម្រាប់គេងយប់ គឺមានអាវដៃវែងពណ៌លឿង។ បាទ គាត់ងើបពីគេង ក៏ប៉ុន្តែគាត់មិនទាន់បាត់ងងុយគេងនោះទេ។ ដោយយើងឃើញថា យើងមើលមាត់របស់គាត់ មាត់របស់គាត់គឺកំពុងតែស្វាប ហើយគាត់កំពុងតែធ្វើកាយវិការ ដើម្បីពត់ខ្លួន។ អញ្ចឹងជាទូទៅ ក្រោយពីយើងងើបពីគេង យើងតែងតែមានអារម្មណ៍ និងមានកាយវិការមួយគឺស្វាបនិងពត់ខ្លួន ហើយយើងមើលមកក្មេងនេះ គាត់កំពុងតែស្វាប ហើយដៃរបស់គាត់មួយចំហៀង គាត់កំពុងតែយកទៅខ្ទប់នឹងមាត់របស់គាត់។ បាទ ហើយមួយចំហៀងទៀតគាត់លើកឡើងលើ ព្រោះ ធ្វើបែបនេះ គឺធ្វើឲ្យយើងមានអារម្មណ៍ថាស្រួលខ្លួនមែនទែន បន្ទាប់ពីយើងងើបពីគេងភ្លាមៗនោះផងដែរ។

ចូលមកដល់រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ បន្ទាប់ពីក្មេងប្រុសនោះ គាត់ងើបពីគេងហើយ។ បាទ គាត់បានដើរចេញពីបន្ទប់គេងរបស់គាត់។ អញ្ចឹងក្មេងប្រុសទី ក្មេងប្រុសនោះ គាត់ដើរចេញពីបន្ទប់គេង គាត់ដើរចូលមកក្នុងបន្ទប់ទឹក។ បាទ យើងឃើញថា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅក្នុងបន្ទប់ទឹករបស់គាត់ គឺមានលក្ខណៈទំនើបផងដែរ។ ហើយក្មេងប្រុសនោះ គាត់ដើរមកក្នុងបន្ទប់ទឹក ដោយនៅក្នុងសម្លៀកបំពាក់គេងរបស់គាត់។ អញ្ចឹងគាត់ស្លៀកសម្លៀកបំពាក់គេង បាទ គឺមានខោជើងវែង ដែលខោជាខោរលុង បានន័យថាខោនោះទូលាយជាងខ្លួនគាត់ ព្រោះថាយើងស្លៀកខោទូលាយ ឬខោរលុង ដើម្បីងាយស្រួលក្នុងការគេង ហើយគាត់ពាក់អាវដៃវែងពណ៌លឿង។ នៅក្នុងដៃរបស់គាត់ គឺមានកាន់កន្សែងពោះគោមួយ អញ្ចឹងនៅពេលណាដែលយើងចូលទៅងូតទឹក ឬក៏ចូលទៅក្នុងបន្ទប់ទឹក យើងគួរតែយកកន្សែងពោះគោទៅតាមខ្លួន ព្រោះថានៅពេលដែលយើងយកកន្សែងពោះគោទៅ នៅពេលដែលយើងងូតទឹករួច ខ្លួនយើងនឹងទទឹក ដូច្នេះយើងយកកន្សែងពោះគោ ដើម្បីទៅជូតខ្លួន។ អញ្ចឹងក្មេងប្រុសម្នាក់នេះ គាត់អាច គាត់បានយកកន្សែងទៅជូតខ្លួនរបស់គាត់នៅក្នុងបន្ទប់ទឹកផងដែរ។ យើងឃើញ បើយើងមើលទៅលើជើងរបស់ក្មេងប្រុសនោះ គឺគាត់មានពាក់ស្បែកជើងផ្ទាត់ អញ្ចឹងបានន័យថានៅក្នុងបន្ទប់របស់គាត់ គឺមានស្បែកជើងផ្ទាត់សម្រាប់ពាក់នៅក្នុងបន្ទប់ ហើយមានស្បែកជើងផ្ទាត់សម្រាប់ពាក់ចូលក្នុងបន្ទប់ទឹក។ ព្រោះគេធ្វើបែបនេះ បានន័យថា នៅទីក្រុង ជាទូទៅ គឺបន្ទប់ទឹកគឺ យើងធ្វើអំពីឥដ្ឋ ហើយនិងមានបិទឥដ្ឋការ៉ូជាមួយផងដែរ។ ដែលឥដ្ឋការ៉ូ គឺនៅពេលដែលត្រូវទឹក គឺ គឺរអិល។ អញ្ចឹងគាត់ត្រូវពាក់ស្បែកជើងផ្ទាត់ ដើម្បីកុំឲ្យរអិល។ ហើយនៅក្នុងបន្ទប់ទឹករបស់គាត់ យើងឃើញថា មានក្រណាត់ជូតជើងផងដែរ អញ្ចឹងគាត់មានក្រណាត់ជូតជើងមួយទៀត ដើម្បីជូតឲ្យស្ងួត មុននឹងដើរលើឥដ្ឋការ៉ូ នៅពេលដែលយើងងូតទឹករួច។ យើងឃើញថា បន្ទប់ទឹករបស់គាត់ ត្រូវបានខណ្ឌចែកចេញជាពីរកន្លែង ដែលមួយ គឺខាងបង្គន់ មួយទៀតកន្លែងងូតទឹក ដោយកន្លែងទាំងពីរនោះ គឺខណ្ឌដោយវាំងននមួយ។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញមានវាំងននមួយ ដែលនៅក្នុងបន្ទប់ដែលមានវាំងននោះ គឺយើងមានឃើញក្បាលទឹកផ្កាឈូក។ អញ្ចឹងក្បាលទឹកផ្កាឈូក គឺជាក្បាលទឹក ដែលសម្រាប់យើងងូតទឹក។ បាទ នៅទីក្រុងគឺយើងប្រើប្រាស់ទឹកផ្កាឈូកដើម្បីងូតទឹក [...] ទឹកផ្កាឈូកគឺតភ្ជាប់ទៅនឹងក្បាលរ៉ូប៊ីនេទឹក ដែលបើកទឹកម៉ាស៊ីនចេញមក។ អញ្ចឹងទឹកម៉ាស៊ីនចេញមកឆ្លងកាត់ក្បាលទឹកផ្កាឈូក យើងអាចងូតបាន ក៏ប៉ុន្តែនៅក្នុងជនបទ គឺគេប្រើប្រាស់ទឹកពាងដើម្បីងូតតែប៉ុណ្ណោះ ព្រោះពុំមានទឹកផ្កាឈូកឬទឹកម៉ាស៊ីននោះទេ។

ចូលដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា ក្មេងប្រុសម្នាក់នោះ គាត់បានចូលទៅកន្លែងងូតទឹក ហើយគាត់យកដៃចុចទៅលើគ្រាប់ចុច ដើម្បីដាក់ឲ្យទឹកក្តៅ។ អញ្ចឹងបានន័យថានៅពេលព្រឹកគឺត្រជាក់។ បាទ ពេលព្រឹកគឺត្រជាក់ ដូច្នេះប្រសិនបើយើងងូតទឹក ប្រសិនបើយើងងូតទឹក គឺយើងត្រូវការទឹកក្តៅ បាទ អញ្ចឹងដោយសារតែក្មេងប្រុសម្នាក់នោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់នៅទីក្រុង អញ្ចឹងហើយគឺឧបករណ៍របស់គាត់ប្រើប្រាស់ទំនើប ដោយមានម៉ាស៊ីនទឹកក្តៅទឹកត្រជាក់ ដោយយើងគ្រាន់តែភ្ជាប់នឹងចរន្តអគ្គិសនីតែប៉ុណ្ណោះ។ បាទ អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់បានចុចទៅលើគ្រាប់ចុច ដើម្បីឲ្យទឹកក្តៅ អញ្ចឹងនៅពេលដែលគាត់ងូត គឺមានអារម្មណ៍ថាកក់ក្តៅ មិនរងានោះទេ។ ព្រោះខែនោះ គឺជាខែរងា ដូច្នេះហើយគាត់ត្រូវការងូតទឹកក្តៅ។ ហើយនៅប្រទេសកម្ពុជា គឺពុំសូវមានម៉ាស៊ីនទឹកក្តៅទឹកត្រជាក់នៅតាមផ្ទះនោះទេ។ ដូច្នេះយើង រាល់ពេលដែលយើងដល់ខែត្រជាក់ ឬក៏ដល់ខែរងា គឺយើងតែងតែដាំទឹកក្តៅ។ អញ្ចឹងគឺយើងយកទឹកក្តៅទៅដាំ ដាំឲ្យពុះ រួចហើយយើងយកមកលាយជាមួយនឹងទឹកត្រជាក់ ដើម្បីឲ្យវាក្តៅអ៊ុនៗ។ បាទ អញ្ចឹងនៅពេលដែលងូតទឹកក្តៅអ៊ុនៗ ធ្វើឲ្យយើងមានអារម្មណ៍ថាកក់ក្តៅ និងមិនរងាខ្លាំងនោះទេនៅក្នុងខែរងា។

ចូលដល់រូបភាពទី ៥ រូបភាពទី ៥ គឺក្មេងប្រុសម្នាក់នោះ គាត់ងូតទឹក បាទ ទឹក គាត់បើកទឹកផ្កាឈូករបស់គាត់ ហើយគាត់ឈរពីក្រោមទឹកផ្កាឈូកនោះ។ អញ្ចឹងយើងឃើញថា ទឹកផ្កាឈូកកំពុងតែបញ្ចេញទឹកទៅលើក្មេងប្រុសម្នាក់នោះ។ ហើយក្មេងប្រុសម្នាក់នោះ គាត់ងូតទឹកដោយរក្សាក្បួនអនាម័យរបស់គាត់ ដែលគាត់បានរៀនពីសាលាមក គឺយើងឃើញថា គាត់ងូតទឹកដោយបានកក់សក់និងដុសខ្លួនផងដែរ។ អញ្ចឹងជារៀងរាល់ពេលដែលយើងងូតទឹក យើងគួរតែដុសខ្លួននឹងសាប៊ូ ហើយក៏ដូចជាកក់សក់នឹងសាប៊ូកក់សក់ផងដែរ។ ព្រោះថាការធ្វើបែបនេះធ្វើឲ្យខ្លួនប្រាណរបស់យើងមានអនាម័យ និងអាចចៀសផុតពីមេរោគផ្សេងៗ ដែលតោងជាប់នឹងខ្លួនយើង ព្រោះថានៅពេលដែលយើងគេង រាងកាយរបស់យើងនឹងបញ្ចេញញើសផងដែរ។ អញ្ចឹងធ្វើឲ្យមានមេរោគឬក៏បាក់តេរីផ្សេងៗ ជាប់នឹងខ្លួនយើង ដូច្នេះនៅពេលដែលយើងងូតទឹក យើងត្រូវតែដុសខ្លួននិងកក់សក់នឹងសាប៊ូ។ ហើយការដុសខ្លួននឹងសាប៊ូក៏ធ្វើឲ្យរាងកាយរបស់យើងមានក្លិនក្រអូបផងដែរ។ ដែលធ្វើឲ្យយើងមានក្លិនក្រអូបនិងមិនមានក្លិនអាក្រក់នៅពេលដែលយើងដើរក្បែរអ្នកដទៃ ព្រោះថានៅពេលដែលយើងមានក្លិនស្អុយឬក៏មានក្លិនខ្លួននៅក្បែរអ្នកដទៃ អ្នកដទៃមិនចូលចិត្តយើងនោះទេ អញ្ចឹងយើងត្រូវងូតទឹកដោយដុសខ្លួននឹងសាប៊ូ។

នៅក្នុងរូបភាពទី ៦ ចូលដល់រូបភាពទី ៦ យើងឃើញថា បន្ទាប់ពីក្មេងប្រុសនោះងូតទឹករួចហើយ អញ្ចឹងក្មេងប្រុសនោះ គាត់ងូតទឹករួច គាត់ក៏បានចេញពីបន្ទប់ទឹកដើម្បីផ្លាស់សម្លៀកបំពាក់។ អញ្ចឹងមុននឹងគាត់ចេញពីបន្ទប់ទឹក គឺគាត់បានជូតខ្លួននឹងកន្សែង។ បាទ គាត់ជូតខ្លួននឹងកន្សែងពោះគោដែលគាត់ដើរយកចូលទៅក្នុងបន្ទប់ទឹករបស់គាត់រួច។ បន្ទាប់មក គាត់ក៏បានមកពាក់ខោអាវវិញ នៅក្នុងរូបភាពនេះគឺមានបី គឺរូបភាពទី ៦ នេះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺរូបដែលនៅខាងឆ្វេងគេបង្អស់ គឺយើងឃើញថាក្មេងប្រុសម្នាក់នោះ គាត់បានពាក់អាវ
គាត់គឺជាសិស្ស ដូច្នេះហើយគាត់បានពាក់ឯកសណ្ឋានសាលារបស់គាត់
អញ្ចឹងឯកសណ្ឋានសាលារបស់គាត់គឺអាវពណ៌ខៀវ បាទ ពណ៌រៀងទឹកសមុទ្របន្តិច ដៃខ្លី អញ្ចឹង
គាត់ពាក់អាវដៃខ្លី ហើយអាវរបស់គាត់នៅខាងឆ្វេងគឺមានហោប៉ៅមួយ។ បាទ
អញ្ចឹងហោប៉ៅតូចមួយនោះគឺសម្រាប់ដាក់លុយ បាទ។ បន្ទាប់មកនៅក្នុងរូបភាពកណ្តាល
ចំណែករូបភាពកណ្តាល គឺគាត់ពាក់អាវធំខាងក្រៅពីលើមួយទៀត។
អញ្ចឹងអាវដែលគាត់ពាក់ខាងក្រៅ យើងហៅថាអាវរងា បាទ ដោយសារតែខែនេះជាខែត្រជាក់
អញ្ចឹងហើយ ដើម្បីរក្សាកម្តៅ ឬក៏ដើម្បីរក្សាភាពកក់ក្តៅ
យើងត្រូវពាក់អាវរងាមួយជាន់បន្ថែមទៀតពីលើអាវឯកសណ្ឋានសាលារបស់យើង។
ព្រោះថាប្រសិនបើយើងមិនពាក់នោះទេ យើងនឹងមានអារម្មណ៍ថារងា ដូច្នេះរងាគឺពិបាកទ្រាំណាស់
អញ្ចឹងយើងត្រូវតែពាក់អាវរងាពីលើ។ អាវរងាជាទូទៅគឺក្រាស់ អញ្ចឹងអាវរងាក្រាស់ ហើយមានដៃវែង
ដូច្នេះវាអាចរក្សាកម្តៅនៅក្នុងខ្លួនយើងឲ្យបានកក់ក្តៅបានយូរ។ នៅក្នុងរូបភាពទី ៦ នៅក្នុងរូបភាពទី
៦ បន្ទាប់ពីគាត់ពាក់អាវរងាពីលើឯកសណ្ឋានសាលារបស់គាត់ហើយ ក្មេងប្រុសម្នាក់នោះ
ក៏បានយកមួកសុវត្ថិភាពមកពាក់មួយជាន់ទៀតផងដែរ។ អញ្ចឹងមួកសុវត្ថិភាពរបស់គាត់
គឺមានពណ៌ទឹកក្រូច។ គាត់ពាក់មួកសុវត្ថិភាពគឺដើម្បីការពារខ្លួន នៅពេលដែលគាត់ជិះម៉ូតូ
ឬកង់ផ្សេងៗ។ អញ្ចឹងគាត់បានរក្សាសុវត្ថិភាពរបស់គាត់ ដោយគាត់ពាក់មួកសុវត្ថិភាព
ហើយរក្សាកម្តៅនៅក្នុងខ្លួនឲ្យមានភាពកក់ក្តៅ ដោយការពាក់អាវរងាពីលើឯកសណ្ឋានសាលា។

ចូលដល់រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា ក្មេងប្រុសម្នាក់នោះ គាត់កំពុងតែជិះម៉ូតូ។
អញ្ចឹងគាត់កំពុងតែទៅសាលារៀន ដោយគាត់កំពុងតែជិះម៉ូតូ ហើយគាត់ពាក់ ស្លៀកខោពណ៌ស
ជើងវែង បាទ។ ហើយគាត់ពាក់មួកសុវត្ថិភាព អញ្ចឹងការពាក់មួកសុវត្ថិភាព គឺជាការគោរពច្បាប់។
បាទ នៅក្នុងច្បាប់ចរាចរណ៍គឺអ្នកជិះម៉ូតូទាំងអស់គឺត្រូវតែពាក់មួកសុវត្ថិភាព
ដើម្បីការពារសុវត្ថិភាពរបស់គេ ការពារជីវិតរបស់គេ។
ព្រោះថាពេលខ្លះគេអាចនឹងមានគ្រោះថ្នាក់ចរាចរណ៍ ប្រសិនបើយើងមិនពាក់មួកសុវត្ថិភាពនោះទេ
គឺអាចនឹងមានគ្រោះថ្នាក់ដល់ក្បាល ដែលធ្វើឲ្យយើងបែកក្បាល ឬក៏មានគ្រោះថ្នាក់ដល់បាត់បង់ជីវិត
ដោយសារការប៉ះទង្គិចក្បាល។ ម្យ៉ាងវិញទៀត ប្រសិនបើយើងមិនពាក់មួកសុវត្ថិភាព
នោះប៉ូលិសនឹងពិន័យយើងជាក់ជាពុំខាន ព្រោះវាផ្ទុយទៅនឹងច្បាប់។ ដូច្នេះ ដើម្បីរក្សាសុវត្ថិភាព
និងដើម្បីគោរពច្បាប់ នៅពេលដែលយើងជិះម៉ូតូ យើងត្រូវពាក់មួកសុវត្ថិភាពទាំងអស់គ្នា។
យើងឃើញថាក្មេងប្រុសម្នាក់នោះ គាត់ក៏បានស្ពាយកាតាបផងដែរ។
អញ្ចឹងនៅខាងក្រោយខ្នងរបស់គាត់គឺមានកាតាបធំមួយ។ បាទ គាត់កំពុងតែស្ពាយកាតាប
ដែលកាតាបនោះគឺជាសម្ភារៈសម្រាប់ដាក់សៀវភៅ ឬក៏ប៊ិច ឬក៏សម្ភារៈសិក្សាផ្សេងៗ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងរាល់សៀវភៅ ប៊ិច ឬក៏សម្ភារៈសិក្សាផ្សេងៗ យើងត្រូវដាក់ក្នុងកាតាប បាទ។
ម៉ូតូរបស់ក្មេងប្រុសនេះគឺមានពណ៌បៃតង ហើយគាត់ដាក់កញ្ចក់ផងដែរ។
អញ្ចឹងកញ្ចក់សម្រាប់មើលក្រោយមួយ ហ្នឹងម៉ូតូគាត់ពណ៌បៃតង គាត់កំពុងតែជិះម៉ូតូទៅសាលា។

នៅក្នុងរូបភាពទី ៨ ចូលដល់រូបភាពទី ៨ ក្មេងប្រុសម្នាក់នោះ
គាត់បានមកដល់សាលារបស់គាត់ហើយ។ អញ្ចឹងគាត់មកដល់សាលារបស់គាត់
ដោយគាត់បានបណ្ដើរម៉ូតូ។ បាទ អញ្ចឹងនៅក្នុងរូបភាពនេះ គឺក្មេងប្រុសម្នាក់នោះ
គាត់កំពុងតែបណ្ដើរម៉ូតូ ដើម្បីទៅកន្លែងចត។ នៅពេលដែលយើងជិះម៉ូតូទៅសាលា
ឬក៏ជិះកង់ទៅសាលា ដើម្បីជាវិន័យ ការគោរពវិន័យ យើងត្រូវបណ្ដើរ ចុះបណ្ដើរម៉ូតូ
ឬក៏ចុះបណ្ដើរកង់ ព្រោះថានៅកម្ពុជា វិន័យសាលាមិនឲ្យជិះម៉ូតូឬក៏ជិះកង់ចូលក្នុងសាលានោះទេ។
ដោយនៅពេលដែលដល់ខ្លោងទ្វារសាលាហើយ សិស្សទាំងអស់ត្រូវចុះបណ្ដើរម៉ូតូឬក៏បណ្ដើរកង់
ដើម្បីទៅកន្លែងចត។ ដូចនៅក្នុងរូបភាពនេះ គឺក្មេងប្រុសម្នាក់នោះ
គាត់ពុំបានជិះម៉ូតូគាត់ចូលក្នុងសាលានោះទេ ព្រោះគាត់បានចុះពីលើម៉ូតូ
រួចបណ្ដើរៗម៉ូតូរបស់គាត់។ បាទ ដោយដៃទាំងពីររបស់គាត់កាន់នូវចង្កូតម៉ូតូ
ហើយគាត់ដើរនៅក្បែរម៉ូតូរបស់គាត់ ដោយកាន់ម៉ូតូបណ្ដើរៗ ហើយគាត់រកកន្លែងចត
ដែលកន្លែងចតនោះគឺយើងឃើញមានម៉ូតូជាច្រើនដែលនៅចតនៅទីនោះ។ បាទ
អញ្ចឹងជាទូទៅកន្លែងចតម៉ូតូគឺគេចតឲ្យមានសណ្ដាប់ធ្នាប់ អញ្ចឹងគេចតជាជួរៗតែម្ដង។
ក្មេងប្រុសម្នាក់នោះត្រូវយកម៉ូតូរបស់គេ ដើម្បីដាក់ចូលជួរម៉ូតូដែលគេកំពុងចតនោះផងដែរ
ដើម្បីរក្សាសណ្ដាប់ធ្នាប់នៅកន្លែងចតម៉ូតូ។

ចូលដល់រូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា ក្មេងប្រុសម្នាក់នោះ
គាត់បានចតម៉ូតូរួចរាល់ហើយ។ អញ្ចឹងបន្ទាប់ពីគាត់ចតម៉ូតូរួចរាល់ហើយ
គាត់បានបើកកែបម៉ូតូរបស់គាត់។ បាទ ម៉ូតូ ជាទូទៅ យើងអាចបើកកែបបាន
ហើយនៅក្រោមកែបម៉ូតូគឺមានឃ្លុបមួយសម្រាប់ដាក់អីវ៉ាន់។ អញ្ចឹង នៅក្នុងរូបភាពនេះ
គឺគាត់កំពុងតែបើកកែបម៉ូតូ ដោយម៉ូតូរបស់គាត់ គឺបើកកែបទាំងអស់តែម្ដង។
អញ្ចឹងការបើកកែបម៉ូតូគឺយើងត្រូវចាក់សោជាមុនសិន។ ទីមួយយើងត្រូវចាក់សោ
បន្ទាប់មកយើងបើកកែបម៉ូតូ។ បាទ នៅក្រោមកែបម៉ូតូ មានម៉ូតូខ្លះ
គឺមានធុងសាំងនៅក្រោមកែបម៉ូតូ។ រីឯម៉ូតូខ្លះ ធុងសាំង គឺនៅខាងមុខម៉ូតូតែម្ដង។
អញ្ចឹងសម្រាប់ម៉ូតូធុនតូច បាទ ការជិះម៉ូតូធុនតូច ធុងសាំងគឺគេដាក់នៅខាងក្រោមកែប។
អញ្ចឹងនៅពេលនេះគាត់បើកកែប គឺគាត់អាចជាមានហេតុផលពីរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺទីមួយគាត់អាចបើកមើលធុងសាំងរបស់គាត់ និងទីពីរគឺគាត់បើកដើម្បីដាក់អីវ៉ាន់ចូលទៅក្នុងឃ្លុប ឬក៏ប្រអប់ដែលនៅក្រោមកែបម៉ូតូ បាទ។

ចូលដល់រូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា បន្ទាប់ពីក្មេងប្រុសម្នាក់នោះ គាត់បើកកែបម៉ូតូរួចរាល់ហើយ គាត់បានដោះមួកសុវត្ថិភាពនិងដោះអាវរងា ដើម្បីដាក់ចូលទៅក្នុងឃ្លុបនៅក្រោមកែបម៉ូតូ។ អញ្ចឹងជាទូទៅ ម៉ូតូនីមួយៗតែងតែមានឃ្លុប ឬក៏ប្រអប់មួយដែលនៅក្រោមកែបសម្រាប់ដាក់អីវ៉ាន់។ ហើយប្រអប់នោះ ម៉ូតូខ្លះមានប្រអប់តូច ម៉ូតូខ្លះមានប្រអប់ធំ។ អញ្ចឹងនៅពេលដែលម៉ូតូដែលមានប្រអប់ធំ គឺយើងអាចដាក់អីវ៉ាន់បានច្រើន បាទ ដូចជាអាវ ដូចជាកាតាប អីអញ្ចឹងគឺ យើងអាចដាក់នៅក្នុងប្រអប់នៅក្រោមកែបម៉ូតូនោះតែម្តង។ ហើយនៅក្រោមកែបម៉ូតូគឺមានធុងសាំង។ អញ្ចឹងនៅពេលណាដែលយើងជិះអស់សាំង ក៏យើងត្រូវបើកកែបម៉ូតូដែរ។ បាទ យើងបើកកែបម៉ូតូដើម្បីចាក់សាំងទៅក្នុងធុងសាំងនោះ។ បាទ ក្មេងប្រុសម្នាក់នេះ គាត់ដាក់អាវរងាររបស់គាត់ចូលទៅក្នុងកែបម៉ូតូ ព្រោះថានៅក្នុងសាលា គឺគេត្រូវពាក់ឯកសណ្ឋានសាលា។ អញ្ចឹងគាត់មិនអាចពាក់អាវរងាចូលទៅក្នុងសាលាបាននោះទេ ព្រោះខុសនឹងវិន័យសាលា។ ដូច្នេះអាវរងា គាត់ត្រូវដោះទុក បន្ទាប់មកគាត់ពាក់តែឯកសណ្ឋានសាលាចូលទៅក្នុងសាលារៀន ដើម្បីរៀននៅក្នុងថ្នាក់តែប៉ុណ្ណោះ។

ចូលដល់រូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា បន្ទាប់ពីក្មេងប្រុសម្នាក់នោះ គាត់បានដាក់សម្ភារៈ ឬក៏ដាក់ខោអាវ ដាក់អាវរងា និងដាក់មួកការពាររបស់គាត់ ចូលទៅក្នុងកែបម៉ូតូហើយ គាត់បានបិទកែបម៉ូតូវិញយ៉ាងយកចិត្តទុកដាក់។ អញ្ចឹងគាត់បិទកែបម៉ូតូនេះគឺដើម្បីកុំឲ្យចំហានូវកែបម៉ូតូគាត់យូរពេក ព្រោះថានៅពេលដែលកែបម៉ូតូគាត់ចំហអាចនឹងក្តៅមកចំម៉ូតូគាត់។ នៅពេលដែលកម្តៅប៉ះម៉ូតូគាត់ ធ្វើឲ្យសាំងម៉ូតូរបស់គាត់ហ្នឹងហួតអស់។ អញ្ចឹងសាំងម៉ូតូ គឺងាយនឹងហួតឡើងលើណាស់។ ដូច្នេះប្រសិនបើយើងមិនបានប្រុងប្រយ័ត្ន វានឹងហួតអស់សាំងម៉ូតូជាមិនខាន។ ម្យ៉ាងវិញទៀតគាត់បិទកែបម៉ូតូ ដើម្បីរក្សាសុវត្ថិភាពសម្ភារៈរបស់គាត់ ដែលបាន គាត់បានដាក់នៅក្រោមកែបម៉ូតូ។ អញ្ចឹងមានដូចជាអាវរងាហើយនិងមួកសុវត្ថិភាព។ អញ្ចឹងប្រសិនបើគាត់មិនបិទកែបម៉ូតូវិញនោះទេ អ្នកដទៃមក ឬក៏ចោរមក វាអាចនឹងយកសម្ភារៈនៅក្នុងកែបម៉ូតូនោះបាត់ទាំងអស់។ អញ្ចឹងគាត់បិទដើម្បីរក្សាសុវត្ថិភាពរបស់សម្ភារៈរបស់គាត់ដែលនៅក្រោមកែបម៉ូតូ។ ម្យ៉ាងវិញទៀត ម៉ូតូត្រូវបិទកែបវិញបន្ទាប់ពីបើករួច ព្រោះថានៅពេលដែលម៉ូតូបើកកែប គឺវាមិនល្អមើលនោះទេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺវាអាក្រក់មើល
ដូច្នេះយើងត្រូវបិទកែបវិញភ្លាមៗបន្ទាប់ពីយើងលែងត្រូវការបើកកែបម៉ូតូនោះទៀតហើយ។

ចូលដល់រូបភាពទី ១២ នៅក្នុងរូបភាពទី ១២ នេះ គឺយើងឃើញមាននាឡិកាចំនួនពីរ ជាមួយនឹងប្រដាប់វាស់សីតុណ្ហភាពចំនួនពីរ ឬក៏យើងហៅថាទែម៉ូម៉ែត្រ។ អញ្ចឹងនៅក្នុងប្រទេសកម្ពុជា គឺនៅក្នុងភាសាខ្មែរ យើងអាចនិយាយថាទែម៉ូម៉ែត្រ ឬក៏ប្រដាប់វាស់សីតុណ្ហភាព បាទ។ អញ្ចឹងនៅក្នុងនោះ យើងឃើញថា នាឡិកាទី ១ គឺមាននៅក្បែរទែម៉ូម៉ែត្រ ឬក៏ប្រដាប់វាស់សីតុណ្ហភាពមួយ។ នាឡិកាទី ១ គឺចង្អុលនូវម៉ោង ៨ បាទ ចង្អុលម៉ោង ៨ គត់ ដែលសីតុណ្ហភាពពេលនោះគឺមានលក្ខណៈត្រជាក់ ព្រោះថាយើងឃើញក្រិតក្រហម បាទ ពណ៌ក្រហម ឆ្នូតក្រហម គឺនៅពាក់កណ្តាលក្រិតនៃទែម៉ូម៉ែត្រ ឬប្រដាប់វាស់សីតុណ្ហភាព។ អញ្ចឹងបានន័យថា សីតុណ្ហភាពពេលនោះគឺត្រជាក់ គឺម៉ោង ៨ ព្រឹក អញ្ចឹងម៉ោង ៨ ព្រឹក គឺសីតុណ្ហភាពត្រជាក់។ ជាធម្មតាខែរងានៅក្នុងប្រទេសកម្ពុជា គឺពេលព្រឹកមានអាកាសធាតុត្រជាក់ខ្លាំង។ បាទ ក៏ប៉ុន្តែដោយសារតែប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយមានអាកាសធាតុក្តៅហើយសើម។ ដូច្នេះ រដូវរងា ឬក៏រដូវត្រជាក់នៅក្នុងប្រទេសកម្ពុជា មិនបណ្តាលឲ្យធ្លាក់ទឹកកកនោះទេ ព្រោះអាកាសធាតុនៅតំបន់ត្រូពិក គឺពុំមានអាកាសធាតុ [...] ត្រជាក់ដល់ធ្លាក់ទឹកកកនោះទេ។ គឺប៉ុន្តែវាអាចត្រជាក់ខ្លាំង បាទ ហើយពេលខ្លះ គឺសីតុណ្ហភាពអាចធ្លាក់ចុះរហូតដល់ ១០ អង្សា ឬក៏ ១៥ អង្សាផងដែរ។ ដូច្នេះគឺមានភាពត្រជាក់ ក៏ប៉ុន្តែមិនអាចធ្លាក់ទឹកកកនោះទេ។ អញ្ចឹងអាកាសធាតុត្រជាក់ ឬក៏កម្រិតនៃអាកាសធាតុត្រជាក់ ឬក៏កម្តៅគេហៅថាសីតុណ្ហភាព។ អញ្ចឹងប្រដាប់វាស់សីតុណ្ហភាព គឺវាស់ ឬក៏ប្រើទែម៉ូម៉ែត្រ គេប្រើសម្រាប់វាស់សីតុណ្ហភាពនៅខាងក្រៅថាតើវាក្តៅឬក៏ត្រជាក់ អញ្ចឹងដូចនេះ យើងមកមើលនាឡិកានេះ គឺនៅពេលដែលម៉ោង ៨ គឺសីតុណ្ហភាពគឺត្រជាក់។ អញ្ចឹងរហូត យើងឃើញថា នាឡិកាបានចង្អុលម៉ោងជិត ១ អញ្ចឹងម៉ោង ១២ និង ៤០ នាទី បាទ ដល់ពេលម៉ោង ១២ និង ៤០ នាទី គឺសីតុណ្ហភាពចាប់ផ្តើមឡើងកម្តៅ គឺយើងឃើញថាទែម៉ូម៉ែត្រ ឬក៏ប្រដាប់វាស់សីតុណ្ហភាព បានបង្ហាញឆ្នូតក្រហមរបស់វាឡើងជិតដល់ខាងលើតែម្តង។ អញ្ចឹងបានន័យថាសីតុណ្ហភាពគឺចាប់ផ្តើមក្តៅឡើងវិញហើយ។

ចូលដល់រូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា វាគឺជាពេលថ្ងៃត្រង់ ព្រោះថាអម្បាញ់មិញយើងឃើញថា ឃើញម៉ោងវា ១២ កន្លះ ឬក៏ ១២ សែសិប។ អញ្ចឹង ១២ សែសិប គឺលើស ១០ នាទី យើង ១២ កន្លះ គឺ ១២ សាមសិបនាទី។ អញ្ចឹងប្រសិនបើម៉ោង ១២ សាមសិបនាទី គឺយើងហៅ ១២ កន្លះ ក៏ប៉ុន្តែអម្បាញ់មិញ គឺម៉ោង ១២ និងសែសិបនាទី បាទ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងម៉ោង ១២ និងសែសិបនាទី គឺជាពេលវេលាមួយដែលកូនសិស្សចេញពីរៀន។
នៅក្នុងប្រទេសកម្ពុជាមានសាលាខ្លះគឺកូនសិស្សនឹងរៀនព្រឹកផង ល្ងាចផង បាទ។
ប៉ុន្តែនៅសាលាខ្លះគឺគេរៀនតែមួយព្រឹកនោះទេ។ ដូច្នេះនៅសាលារៀន គេចូលរៀនម៉ោង ៧ ព្រឹក
និងចេញម៉ោង ១១។ ក៏ប៉ុន្តែសម្រាប់តែសាលាដែលគេបង្រៀនពីរវេន បាទ គឺព្រឹក ល្ងាច
គឺគេចូលម៉ោង ៧ ចេញម៉ោង ១១ និងចូលម៉ោង ១ ចេញម៉ោង ៥។ ដូច្នេះនៅក្នុងរូបភាពនេះ
គឺយើងអាចនិយាយថា សិស្សគឺដល់ពេលសម្រាកញ៉ាំបាយនៅពេលថ្ងៃត្រង់។ អញ្ចឹង
ពួកគាត់ចេញពីសាលារៀន។ យើងឃើញនៅក្នុងនេះ យើងឃើញនៅក្នុងរូបភាពនេះ
គឺមានសាលារៀនមួយ បាទ មានអគារសាលារៀនមួយ ដែលនៅក្នុងនោះ គឺយើងឃើញមានពីរជាន់
អគារនោះគឺពីរជាន់ បាទ ហើយមានប្រាំមួយបន្ទប់។ អញ្ចឹង មានថ្នាក់រៀនចំនួនប្រាំមួយបន្ទប់។
ហើយនៅលើអគារនោះ យើងឃើញមានព្រះអាទិត្យចំនួនមួយ អញ្ចឹងបានន័យថា
ព្រះអាទិត្យរះនៅកម្ពស់ថ្ងៃត្រង់ បាទ អញ្ចឹងគឺជាពេលវេលាថ្ងៃត្រង់។
ហើយយើងឃើញមានសិស្សជាច្រើន គាត់បានដើរចេញពីអគារសាលានោះ។
អញ្ចឹងបានន័យថាដល់ម៉ោងដែលគាត់សម្រាក ដូច្នេះគាត់ត្រូវដើរចេញពីអគារទៅផ្ទះ
ឬក៏ទៅកន្លែងញ៉ាំបាយ។ បាទ សិស្សខ្លះដែលមានផ្ទះជិតគឺគាត់ទៅផ្ទះរបស់គាត់
ចំណែកឯសិស្សដែលមានផ្ទះឆ្ងាយ គឺគាត់ទៅកន្លែងញ៉ាំបាយ ឬក៏គេហៅថាអាហារដ្ឋាន។
អញ្ចឹងជាទូទៅសាលានីមួយៗតែងតែមានអាហារដ្ឋានរបស់គេ
សម្រាប់ឲ្យសិស្សានុសិស្សចូលញ៉ាំអាហារ។ យើងឃើញនៅពីមុខអគារនេះ គឺមានដងទង់ជាតិមួយ
បាទ អញ្ចឹងបង្គោលខ្ពស់មួយនោះ គេហៅថាដងទង់ជាតិ
ដែលយើងឃើញមានទង់ជាតិចងនៅដងបង្គោលនោះ កំពុងតែបក់រវិចៗ។
អញ្ចឹងទង់ជាតិគឺដាក់នៅគ្រប់សាលាតែម្តង។ ហើយជាទូទៅមុនពេលចូលរៀន
គឺសិស្សទាំងអស់ត្រូវតែគោរពទង់ជាតិ គឺយើងត្រូវបង្ហូតទង់ជាតិឡើងដោយច្រៀងចម្រៀងជាតិ
ដូចជានៅក្នុងសាលានៅក្នុងប្រទេសកម្ពុជា គឺពេលព្រឹកម៉ោង ៧
នៅពេលដែលសិស្សចូលដល់សាលាអស់ គឺសិស្សទាំងអស់ ត្រូវមកតម្រង់ជួរគ្នានៅក្បែរទង់ជាតិ
ដើម្បីច្រៀងភ្លេង ច្រៀងបទភ្លេងជាតិ ហើយបង្ហូតទង់ជាតិឡើងលើនៅពេលព្រឹក។
អញ្ចឹងបទភ្លេងជាតិរបស់ប្រទេសកម្ពុជា គឺមានចំណងជើងថាបទនគររាជ។
អញ្ចឹងគឺយើងតែងតែច្រៀង ដើម្បីបង្ហូតទង់ជាតិឡើងលើនៅពេលព្រឹក។ ហើយបន្ទាប់មក
នៅពេលដែលសិស្សចេញពីរៀននៅពេលល្ងាច គឺយើងត្រូវបង្ហូតទង់ជាតិចុះវិញ
ដោយច្រៀងបទនគររាជដដែល។ អញ្ចឹងនៅគ្រប់សាលាទាំងអស់ គឺត្រូវបង្ហូតទង់ជាតិពីរដង
ទីមួយគឺនៅពេលព្រឹកម៉ោង ៧ និងទីពីរនៅពេលល្ងាចម៉ោង ៥ ឬក៏នៅពេលរសៀល។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចូលដល់រូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ គឺយើងឃើញថាម៉ោង ១២ បាទ ម៉ោង ១២
សែសិបនាទី គឺមានអាកាសធាតុក្តៅ។ អញ្ចឹងយើងឃើញក្មេងប្រុសម្នាក់ យើង មាន
ឃើញក្មេងប្រុសម្នាក់ បាទ គាត់កំពុងតែស្លៀកឯកសណ្ឋានសាលារបស់គាត់
ដោយគាត់ពាក់អាវដៃខ្លីពណ៌ទឹកសមុទ្រ ហើយនៅខាងឆ្វេងដៃគឺមានហោប៉ៅមួយ។
អញ្ចឹងអាវគាត់មានហោប៉ៅ កូនហោប៉ៅតូចមួយ នៅខាងឆ្វេង។
ក្មេងប្រុសម្នាក់នោះដើរដោយអាការៈបែកញើស គាត់មានស្ពាយកាតាបមួយនៅខាងក្រោយខ្នង
ដែលកាតាបនោះគឺពណ៌ស។ យើងឃើញថាក្មេងប្រុសនោះដើរក្រោមកម្តៅថ្ងៃ
ដោយនៅក្នុងរូបភាពនេះយើងឃើញមានព្រះអាទិត្យមួយកំពុងតែបញ្ចេញកម្តៅ។
ហើយគាត់ដើរបណ្តើរ គឺយកដៃឆ្វេង ដៃស្តាំរបស់គាត់ បាទ គាត់យកដៃស្តាំរបស់គាត់
ចាប់កអាវរបស់គាត់ ដើម្បីរលាស់ឡើង។ អញ្ចឹងនៅពេលដែលគាត់ដើរក្រោមកម្តៅ
គឺមានអាកាសធាតុក្តៅ យើងឃើញថាគាត់បែកញើសច្រើន
អញ្ចឹងហើយគាត់យកដៃរបស់គាត់មួយចំហៀង ចាប់កអាវរបស់គាត់ដើម្បីរលាស់
ធ្វើយ៉ាងណាឲ្យមានខ្យល់ចូលនៅក្នុងអាវរបស់គាត់ដើម្បីឲ្យត្រជាក់ខ្លួន។
អញ្ចឹងគាត់ធ្វើបែបនេះដើម្បីឲ្យមានខ្យល់ចូលនៅក្នុងអាវ ដើម្បីឲ្យត្រជាក់ខ្លួនរបស់គាត់។
ព្រោះតែប្រទេសកម្ពុជានៅក្នុងតំបន់ត្រូពិក ហើយមានអាកាសធាតុក្តៅហើយសើម ដូច្នេះហើយ
នៅពេលដែលត្រូវកម្តៅ គឺខ្លួនប្រាណរបស់យើងងាយនឹងបែកញើសជាច្រើន។ បាទ
ដោយសារតែមាន យើងមានសំណើមនៅក្នុងខ្លួនជានិច្ចតាមរយៈអាកាសធាតុ អញ្ចឹង
នៅពេលដែលត្រូវកម្តៅ គឺញើសនឹងបញ្ចេញមក អញ្ចឹងទឹកដែលចេញពីខ្លួន យើងហៅថាញើស
ដូចនៅក្នុងរូបភាពនេះ ក្មេងប្រុសម្នាក់នោះ គាត់ដើរក្រោមកម្តៅថ្ងៃក្តៅខ្លាំង។ ដូច្នេះហើយ
គាត់បែកញើសហូរយ៉ាងច្រើន អញ្ចឹងគាត់ហូរញើស ឬក៏បែកញើសយ៉ាងច្រើន
ចេញពីមុខរបស់គាត់។ ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺមុខរបស់គាត់បញ្ចេញទឹកមកជាច្រើន
ដែលជាញើសនោះ។ ហើយគាត់បានយកដៃចាប់កអាវរបស់គាត់ដើម្បីរលាស់
ធ្វើយ៉ាងណាឲ្យខ្លួនគាត់ត្រជាក់។

ចូលដល់រូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា នៅក្នុងរូបភាពនេះ
គឺនិយាយអំពីផ្ទះមួយ បាទ ដែលនៅក្នុងផ្ទះនោះគឺមាននាឡិកាមួយ គឺចង្អុលម៉ោង ៦ និងលើសបន្តិច
បាទ ប្រហែលជាម៉ោង ៦ ពីរនាទី។ បាទ អញ្ចឹងនៅក្នុងរដូវត្រជាក់ នៅពេលដែលម៉ោង ៦
នៅពេលដែលល្ងាច គឺសីតុណ្ហភាពចាប់ផ្តើមចុះត្រជាក់វិញ។ បាទ អញ្ចឹងពេលព្រឹកពីម៉ោង ៧
ពីម៉ោង ៧ ទៅ គឺចាប់ផ្តើមសីតុណ្ហភាពត្រជាក់ រហូតដល់ម៉ោង ១០ រហូតទៅដល់ម៉ោងល្ងាច ម៉ោង
៥ គឺសីតុណ្ហភាពចាប់ផ្តើមឡើងកម្តៅវិញ។ អញ្ចឹងពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ១០ ព្រឹក
គឺមានអាកាសធាតុត្រជាក់។ ចំណែកចាប់ពីម៉ោង ១០ ព្រឹក រហូតទៅដល់ម៉ោង ៥ ល្ងាច

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺមានសីតុណ្ហភាពក្តៅខ្លាំង អញ្ចឹងទោះជារដូវរងាក៏សីតុណ្ហភាពក្តៅដែរ ប៉ុន្តែចាប់ពីម៉ោង ៥ ល្ងាច រហូតដល់ម៉ោង ៥ ព្រឹក គឺអាកាសធាតុចាប់ផ្តើមត្រជាក់ ហើយត្រជាក់ខ្លាំងជាងពេលព្រឹកទៀត។ អញ្ចឹងនៅក្នុងរដូវរងាគឺសីតុណ្ហភាពគឺត្រជាក់ច្រើនជាងក្តៅ នៅក្នុងរូបភាពនេះយើងឃើញថាគឺម៉ោង ៦ ល្ងាច ដោយយើងឃើញនៅតាមបង្អួច បាទ បង្អួចដែលបើកវាំងននោះ គឺយើងឃើញព្រះអាទិត្យកំពុងតែលិចនៅក្បែរភ្នំ។ អញ្ចឹងចាប់ផ្តើមពីពេលម៉ោង ៥ ទៅ គឺព្រះអាទិត្យចាប់ផ្តើមលិច ហើយព្រះអាទិត្យលិចនៅទិសខាងលិច ព្រះអាទិត្យរះនៅទិសខាងកើត។ អញ្ចឹងពេលម៉ោង ៧ ព្រឹក គឺព្រះអាទិត្យចាប់ផ្តើមរះ ចំណែកម៉ោង ៥ ល្ងាច គឺព្រះអាទិត្យចាប់ផ្តើមលិច។ អញ្ចឹងបានន័យថា នៅពេលដែលព្រះអាទិត្យលិច គឺជាពេលយប់ហើយ។ បាទ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថាមានផ្ទះមួយ ដែលនៅក្បែរជើងភ្នំ ហើយព្រះអាទិត្យកំពុងតែលិចនៅក្បែរភ្នំនោះផងដែរ។ បាទ មើលទៅគឺរូបភាពនេះគឺស្រស់ស្អាត ដោយសារតែបង្ហាញអំពីទេសភាពនាពេលថ្ងៃលិច។

ចូលដល់រូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា ម៉ោង ៦ ល្ងាច ដូច្នេះសិស្សត្រូវចេញពីសាលាហើយ។ អញ្ចឹងយើងឃើញក្មេងប្រុសដដែលនោះ បាទ គាត់បានជិះម៉ូតូត្រលប់មកផ្ទះវិញ។ គឺគាត់ជិះម៉ូតូដោយដៃរបស់គាត់កាន់ចង្កូតម៉ូតូ ភ្នែករបស់គាត់សម្លឹងទៅមុខត្រង់ ហើយម៉ូតូរបស់គាត់គឺមានកញ្ចក់មើលក្រោយមួយផងដែរ ដើម្បីមើលសុវត្ថិភាពនៅខាងក្រោយ។ ក្មេងប្រុសម្នាក់នោះ គាត់ជិះម៉ូតូ ដោយពាក់មួកសុវត្ថិភាពពណ៌ស បាទ ហើយគាត់ពាក់អាវរងា។ អញ្ចឹងទោះបីជាពេលល្ងាចក៏ដោយ ក៏គាត់ត្រូវតែពាក់អាវរងា ព្រោះថានៅពេលល្ងាចគឺសីតុណ្ហភាពត្រជាក់ជាងពេលព្រឹក។ ដូច្នេះដើម្បីរក្សាភាពកក់ក្តៅ គាត់ត្រូវតែពាក់អាវរងារបស់គាត់ជាប់ជានិច្ចនៅពេលដែលគាត់ជិះម៉ូតូ ព្រោះនៅពេលដែលជិះម៉ូតូ គឺមានខ្យល់យ៉ាងច្រើន ឬក៏ខ្យល់ខ្លាំងមកប៉ះនឹងខ្លួនយើង។ ហើយខ្យល់នោះគឺមានភាពត្រជាក់ ដូច្នេះហើយវាអាចធ្វើឲ្យយើងរងាបាន។ អញ្ចឹងគាត់ត្រូវតែពាក់អាវរងានៅពេលដែលគាត់កំពុងតែជិះម៉ូតូដើម្បីរក្សាភាពកក់ក្តៅ។ បាទ ហើយគាត់ជិះម៉ូតូ ហើយគាត់ស្ពាយកាតាបមួយផងដែរ អញ្ចឹងនៅពេលដែលគាត់ទៅរៀន គាត់យកកាតាបទៅ ពេលដែលគាត់មកផ្ទះវិញ គាត់ត្រូវតែយកកាតាបមកផ្ទះវិញផងដែរ។ បាទ អញ្ចឹងបានន័យថានៅក្នុងរូបភាពនេះ គឺក្មេងប្រុសនោះ គាត់ចេញពីសាលារៀនហើយ អញ្ចឹងគាត់ត្រូវតែមកផ្ទះវិញដោយជិះម៉ូតូរបស់គាត់ ព្រោះថាការជិះម៉ូតូគឺធ្វើឲ្យយើងចំណេញពេលវេលា នៅពេលដែលយើងដើរគឺចំណាយពេលយូរនិងហត់។ ដូច្នេះគាត់ជិះម៉ូតូ ធ្វើឲ្យគាត់ចំណេញពេលវេលាមកដល់ផ្ទះបានលឿន។ បាទ បន្ទាប់ពីគាត់ជិះម៉ូតូចេញពីសាលា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅពេលដែលគាត់មកដល់ផ្ទះ នោះគាត់នឹងទទួលទាននូវអាហារពេលល្ងាច
ឬក៏និយាយលេងជាមួយនឹងក្រុមគ្រួសាររបស់គាត់ នៅក្នុងផ្ទះតាមទម្លាប់ជាក់ជាពុំខាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.